**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
**លេខៈ** ០១០/១៤ សរ៦៩.៣៧៧

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤

ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ វេលាម៉ោង៨ និង ៣០នាទី នៅវិមានសន្តិភាពមានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងៈ

**១- សេចក្តីព្រាងយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨**
**២- សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥**
**៣- សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣**
**៤- បញ្ហាផ្សេងៗ**

## ១- សេចក្តីព្រាងយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨

នៅក្នុងអំឡុងមួយទសវត្សរ៍ចុងក្រោយនេះព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃ សន្តិភាព ឯកភាពជាតិ និងស្ថិរភាពនយោបាយដែលជាសមិទ្ធផលប្រវត្តិសាស្ត្រនៃគោលនយោបាយឈ្នះ ឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ លើមូលដ្ឋាននេះក្នុងទស្សវត្សរ៍កន្លងមកកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ប្រមាណ៨% ក្នុងមួយឆ្នាំ និងការកាត់បន្ថយភាពក្រីក្រជាង២%ក្នុងមួយឆ្នាំ ដែលជាសមិទ្ធផលគួរជាទីមោទនៈមួយក្នុងចំណោមបណ្តាប្រទេសដែលមានការអភិវឌ្ឍទាបនានាលើសកលលោក។ ដើម្បីបន្តធានាឲ្យបាននូវចីរភាព និងវឌ្ឍនភាពទាំងនេះ ក្នុងទិសដៅប្រែក្លាយកម្ពុជាឲ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ក៏ដូចជាដើម្បីធានាស្ថិរភាពនិងចីរភាពថវិកាសម្រាប់បម្រើសេចក្តីត្រូវការនៃចំណាយសាធារណៈចាំបាច់នានា ការពង្រឹងការប្រមូលចំណូលក្នុងស្រុកនឹងដើរតួនាទីជាគន្លឹះដ៏សំខាន់បំផុតមួយ។

យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យមនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងៈ

(១)- ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ ដើម្បីកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចគោលដៅ

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខៈ ០២៣ ២១២ ៤៩០, ទូរស័ព្ទៈ ០១២ ៨៩៩ ៩០៦, ០៩៧ ៧ ៩៨០ ៦០៤
អ៊ីមែលៈ pressocm@gmail.com

អភិវឌ្ឍន៍ជាតិដែលស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ (២)-ពង្រឹងលំហថវិកា ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់គ្រងបំណុលប្រកបដោយចីរភាព និងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស និង (៣)- បង្កើនធនធានថវិកាសម្រាប់តម្រូវការបន្ទាន់, ករណីប្រធានស័ក្តិ និងវិបត្តផ្សេងៗ ឬតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត។

លើមូលដ្ឋាននេះរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅ «ប្រមូលចំណូលចរន្តសរុបឲ្យកើនបាន០,៥ពិន្ទុភាគរយ គិតជាផលធៀបរវាងចំណូលចរន្ត នឹងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ដោយត្រូវកើនពី ១៥,២០% នៃផសសនៅឆ្នាំ ២០១៤ ដល់១៧,៣៦% នៃផសស នៅឆ្នាំ២០១៨»។ ដើម្បីសម្រេចនូលគោលដៅខាងលើនេះសេចក្តីព្រាងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ ផ្តោតការយកចិត្តទុកដាក់ជាអាទិភាពលើវិធានការពង្រឹងរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ និងការលើកកម្ពស់វប្បធម៌បង់ពន្ធនិងការគោរពច្បាប់ សំដៅប្រមូលចំណូលពន្ធគយ, ចំណូលពន្ធដារ និងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព ឲ្យអស់សក្តានុពលហើយនឹងឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ច ទីផ្សារដែលកំពុងលូតលាស់ និងការកើនឡើងនៃចំនួនអ្នកបង់ពន្ធ ក៏ដូចជាភាពស្មុគស្មាញនៃសកម្មភាពធុរកិច្ចក្នុងសម័យទំនើប។

សេចក្តីព្រាង «ឯកសារយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨» ត្រូវបានរៀបចំឡើងចាប់តាំងពី២០១៣ ដោយទទួលបានការសហការយ៉ាងជិតស្និទ្ធពីអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់, ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ដែលមានតួនាទីភារកិច្ចក្នុងការប្រមូលចំណូលព្រមទាំងបានទទួលនូវមតិយោបល់មួយចំនួនពីដៃគូអភិវឌ្ឍន៍អន្តរជាតិ។

## ២- សេចក្តី ព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

ការអនុវត្តថវិកាឆ្នាំ ២០១៤ បានបង្ហាញឲ្យឃើញនូវការកែទម្រង់ស៊ីជម្រៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងនោះរួមមាន ការពង្រឹងការប្រមូលចំណូលគយ និងពន្ធដារការតម្លើងបៀវត្សជូនមន្ត្រីរាជការ យោធិននគរបាលជាតិ និងនិវត្តជន ជាពិសេសជូនគ្រូបង្រៀននិងគ្រូពេទ្យ ទន្ទឹមនឹងការធ្វើការកែទម្រង់ប្រព័ន្ធបៀវត្សជូនមន្ត្រីរាជការបានទាន់ពេលវេលាក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ។ ក្នុងប្រតិបត្តិការចំណាយសាធារណៈគោលការណ៍បង្កើនប្រសិទ្ធភាព និងវិចារណកម្មចំណាយក៏ត្រូវបានប្រកាន់យ៉ាងខ្ជាប់ខ្ជួន។ ដោយឡែក ការកែទម្រង់ក្នុងវិស័យអប់រំ សន្តិសុខ ការពារជាតិ ពាណិជ្ជកម្ម និងបរិស្ថាន ព្រមទាំងការកែលម្អអភិបាលកិច្ចត្រូវបានចាប់ផ្តើមអនុវត្តគួឲ្យកត់សម្គាល់នៅក្នុងទិសដៅត្រឹមត្រូវ និងកំពុងបង្ហាញលទ្ធផលជាបណ្តើរ ហើយនឹងបន្តអនុវត្តទៅមុខប្រកបដោយជវភាព។ ជារួមក្នុងឆ្នាំ២០១៥ ការកែទម្រង់ត្រូវបានចាប់ផ្តើមនៅគ្រប់ក្រសួងស្ថាប័នរដ្ឋ ដោយប្រកាន់យកនូវអភិក្រមការងារទាំងបួនគឺ *«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល»* ។ ទាំងនេះ គឺជាបុរេលក្ខខណ្ឌដ៏ចាំបាច់ដែលនាំ

ឲ្យសម្រេចបាននូវសុខដុមនីយកម្មខាងនយោបាយ និងធានាបាននូវចលនការនៃការអភិវឌ្ឍឲ្យឈានឆ្ពោះទៅមុខជានិច្ច។

នៅឆ្នាំ២០១៤ តាមការប៉ាន់ស្មានបឋម កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានរង្វង់៧% ក្នុងនោះ៖ ទី១. វិស័យឧស្សាហកម្មទទួលបានកំណើនប្រមាណ៩,៦% ដោយសារការនាំចេញផលិតផលវាយនភ័ណ្ឌមានកំណើនខ្ពស់ហើយផ្នែកសំណង់មានការកើនឡើងគួឲ្យកត់សម្គាល់ ទី២. វិស័យសេវាមានកំណើន៧,៥% ដោយការរួមចំណែកពីកំណើនខាងផ្នែកពាណិជ្ជកម្ម ផ្នែកសណ្ឋាគារ និងភោជនីដ្ឋាន ផ្នែកអចលនទ្រព្យ ផ្នែកធនាគារ និងភាពប្រសើរឡើងនៃប្រព័ន្ធឡូជីស្ទិក ទី៣. វិស័យកសិកម្មអាចសម្រេចបានកំណើន២,៦% ដោយសារពិពិធកម្មនៃការដាំដុះ និងការកើនឡើងនៃផលិតភាព។

ទុនបម្រុងអន្តរជាតិត្រូវបានរំពឹងថា នឹងឈានដល់៤,៥៩៣ពាន់លានដុល្លារអាមេរិក នៅឆ្នាំ ២០១៤ និងព្យាករថានឹងកើនឡើងដល់ ៥,១៤៣ពាន់លានដុល្លារអាមេរិកនៅឆ្នាំ ២០១៥ ដែលរក្សាធានាបានការនាំចូលប្រមាណ៤,៥ខែ នៅឆ្នាំ២០១៤ និងឆ្នាំ២០១៥។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានរៀបចំនៅក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងធ្វើដំណើរនៅលើគន្លងនៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ព្រមទាំងធានា និងរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ សាមគ្គីភាព និងការបង្រួបបង្រួមជាតិ ដោយផ្អែកលើភាពចាស់ទុំខាងនយោបាយ។

ទន្ទឹមនឹងនេះសេដ្ឋកិច្ចកម្ពុជាក៏បានឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ គឺកំពុងក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាប និងស្ថិតក្នុងដំណើរផ្លាស់ប្តូរជារចនាសម្ព័ន្ធ។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសប្រាំបីក្នុងពិភពលោក ដែលត្រូវបានស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ចាត់ទុកថា ជាប្រទេសដែលមានភាពធន់នៃកំណើនសេដ្ឋកិច្ចខ្ពស់បំផុត(Olympian of growth)។ នៅក្នុងក្របខណ្ឌនេះ កម្ពុជាត្រូវធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំប្រកបដោយបរិយាប័ន្ន ដែលជាមូលដ្ឋានមិនអាចខ្វះបាន សម្រាប់ការបង្កើតការងារ និងឱកាសរកប្រាក់ចំណូលសមរម្យ ព្រមទាំងការបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនទូទៅឲ្យកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ក៏ដូចជាការពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃសេវាសាធារណៈ ព្រមទាំងការធ្វើឲ្យកាន់តែប្រសើរឡើងនូវបរិស្ថានវិនិយោគ និងធុរៈកិច្ច។ ជាមួយគ្នានេះដែរ កម្ពុជាក៏មានភាពចាំបាច់ក្នុងការរៀបចំខ្លួនដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែង ក្នុងក្របខណ្ឌពិភពលោក និងក្របខណ្ឌតំបន់ជាពិសេសការចាប់ផ្តើមសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥។ ចំណាយថវិការដ្ឋសរុបត្រូវបានគ្រោងចំនួន១៥ ៦៩៩ ៥២៩លានរៀល ស្មើនឹង២១,០៩% នៃផសស និងមានកំណើន ១០,៨% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៤។ សេចក្តីព្រាងច្បាប់នេះមាន៦ជំពូក និង១៧មាត្រា ក្នុងនោះ មានការស្នើសុំវិសោធនកម្មមាត្រា៤៧ នៃច្បាប់ ស្តីពីសារពើពន្ធដើម្បីតម្លើងកម្រិតបៀវត្សលើកលែងពន្ធ (អត្រាពន្ធ0%) ពី៥០០ ០០០រៀល ទៅ ៨០០.០០០រៀល លើសពីនេះសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការ

តម្លើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ទន្ទឹមនឹងការបង្កើនចំណាយលើវិស័យអប់រំ ការអប់រំ ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, វិស័យសុខាភិបាល វិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់ដែលជាមូលដ្ឋានគ្រឹះនៃការជំរុញកំណើន និងការប្រកួតប្រជែងរបស់កម្ពុជា។

សរុបមកថវិកាឆ្នាំ ២០១៥ អាចប្រសិទ្ធនាមបានថា « ជាថវិកានៃការបោះជំហានទៅមុខយ៉ាងស្វាហាប់ក្នុងដំណើរការផ្លាស់ប្តូររបស់កម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព ការគិតគូរអំពីតុល្យភាពនៃកំណើនសេដ្ឋកិច្ច និងការបែងចែកផលនៃកំណើននេះ ផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងការគិតគូរដល់ការអភិវឌ្ឍរយៈពេលវែង ក្នុងបរិការណ៍សមាហរណកម្មស៊ីជម្រៅក្នុងតំបន់ ការវិវឌ្ឍនៃសកលភាវូបនីយកម្ម ក៏ដូចជាការពង្រឹងសមត្ថភាពគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឲ្យស្របទៅនឹងដំណាក់កាលថ្មីរបស់កម្ពុជា»។

## ៣- សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ គឺជាការឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំឡើងដោយគោរពទាំងស្រុង ទាំងកាលវសាន ទាំងខ្លឹមសារនៃមាត្រា៧៨នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដោយផ្អែកលើការបូកសរុប ទិន្នន័យចំណូល និងចំណាយថវិកាដែលត្រូវបានកត់ត្រាដោយគណនេយ្យករសាធារណៈ និងការផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃទិន្នន័យទាំងនេះជាមួយអាណាប័កពាក់ព័ន្ធ ទាំងក្នុងកម្រិតថវិកាថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផ្អែកតាមទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៣ បានបន្តកើនឡើងយ៉ាងរឹងមាំ ដោយសម្រេចបានកំណើន៧,៤% ធៀបនឹងការព្យាករណ៍ប្រមាណ៧% ទោះបីសេដ្ឋកិច្ចពិភពលោកនៅបន្តប្រឈមនឹងភាពមិនច្បាស់លាស់បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុ និងវិបត្តិបំណុលដែលកើតមានឡើងនាឆ្នាំកន្លងមក។ ជាលទ្ធផល ផសស សម្រាប់មនុស្សម្នាក់ៗ បានកើនឡើងពី៩៧៣ដុល្លារអាមេរិកនៅឆ្នាំ២០១២ដល់១០៤៣ដុល្លារអាមេរិកនៅឆ្នាំ ២០១៣ ទន្ទឹមនេះអតិផរណាជាមធ្យមប្រចាំឆ្នាំរក្សាបាន៣% ដែលតាមការគ្រោងទុកគឺក្នុងរង្វង់៥% និងអត្រាប្តូរប្រាក់ជាមធ្យមរក្សាបាន៤០២៥រៀល ក្នុងមួយដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៣ដែលតាមការគ្រោងទុកគឺ ៤០៥០រៀល។

ចំណូលថវិការថ្នាក់ជាតិឆ្នាំ ២០១៣ អនុវត្តបានចំនួន ១៣ ៣៦០ ៥៣៩, ០លានរៀល ស្មើនឹង២១,៧៦% នៃផសស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ១០,៥% ហើយបានកើនឡើង៨,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០១២។

## ៤- បញ្ហាផ្សេងៗ៖

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានមានប្រសាសន៍ផ្តាំផ្ញើដល់មេបញ្ជាការកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់ចែកផ្តល់អាវរងារជូនដល់ពលទាហាន និងនគរបាលឲ្យបានទាន់ពេលរដូវរងារមកដល់។

**សម្តេចតេជោនាយករដ្ឋមន្ត្រី**បានណែនាំដល់ក្រសួងមហាផ្ទៃស្ថាប័នពាក់ព័ន្ធ ពិសេសសាលារាជធានីភ្នំពេញត្រូវយកចិត្តទុកដាក់រៀបចំរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋបានសប្បាយរីករាយក្នុងឱកាសប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែនាថ្ងៃទី០៥ ០៦ ០៧ វិច្ឆិកា ឆ្នាំ ២០១៤ ខាងមុខនេះ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោ១២ និង៣៥ នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៤